ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី

លេខ: ១០០៧ សជណ

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៥

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

ជម្រាបជូន

ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

កម្មវត្ថុ: អំពីការប្រមូលពន្ធប្រថាប់ត្រាតាមអត្រា ៤ %

យោង : - លិខិតលេខ ២៤៩៩ សហវ ចុះថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ២០០៥ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- ចំណារដ៏ខ្ពង់ខ្ពស់របស់សម្តេចនាយករដ្ឋមន្ត្រីចុះថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ២០០៥

តបតាមកម្មវត្ថុ និងយោងខាងលើ ទីស្តីការគណៈរដ្ឋមន្ត្រីសូមជម្រាបឯកឧត្តមរដ្ឋមន្ត្រីជ្រាបថា រាជរដ្ឋាភិបាល បានឯកភាពជាគោលការណ៍ដូចខាងក្រោម:

១- រក្សាទុកការប្រមូលពន្ធប្រថាប់ត្រាឱ្យស្ថិតនៅស្ថានភាពដូចមុន នៅក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដដែល។ ជាមួយនេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវពង្រឹងការអនុវត្តន៍ការប្រមូលពន្ធប្រថាប់ត្រាបច្ចុប្បន្នឱ្យកាន់តែមានប្រសិទ្ធិភាព ។

២- អង្គភាពក្រោមឱវាទក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវចូលរួមសហការជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីធ្វើការប្រមូលពន្ធនេះមានប្រសិទ្ធិភាព ។

សេចក្តីដូចបានជម្រាបជូនខាងលើសូមឯកឧត្តមមេត្តាជ្រាប និងចាត់ចែងអនុវត្តតាមការគួរ ។

ជ.រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

ប៊ុន ស៊ុយ

ទទួលជូន :

- ក្រសួងមហាផ្ទៃ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ឯកសារ-កាលប្បវត្តិ